ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១២៦/១០-ភី វ៉ាយ អ៊ិនធើណេសិនណល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **យូ សូនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ភី វ៉ាយ អ៊ិនធើណេសិនណល**

អាសយដ្ឋាន : មណ្ឌល ១ សង្កាត់ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

ទូរស័ព្ទ : ០១២ ៦២៦ ៨៦៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោកស្រី Can Py Liu | នាយករងក្រុមហ៊ុន |
| ២- លោក ហំ ភា | មេធាវី |
| ៣- លោក អ៊ឹង ម៉េងហ៊ុយ | គ្រប់គ្រងទូទៅ |
| ៤- លោក ជាតិ ខេមរ៉ា | មន្ត្រីសមាគមរោងចក្រកាត់ដេរកម្ពុជា |
| ៥- លោក រឹម វីរៈ | ជំនួយការមេធាវី |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ**

- **សហជីពសិទ្ធិប្រយោជន៍កម្មករ នៃរោងចក្រ ភី វ៉ាយ**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ⋄ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ⋄ Website: www.arbitrationcouncil.org

អាសយដ្ឋាន : មណ្ឌល ១ សង្កាត់ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

ទូរស័ព្ទ : ០១៧ ៤៣០ ៣១២ ទូរសារ : គ្មាន

តំណាងភាគីកម្មករនិយោជិត: **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សំណើសុំឱ្យក្រុមហ៊ុនទទួលយកលោក ម៉ៅ ពិសិដ្ឋ ជាថ្នាក់ដឹកនាំសហជីពសិទ្ធិប្រយោជន៍កម្មករ ដែលជាប់ឆ្នោតកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ដែលត្រូវក្រុមហ៊ុនបញ្ឈប់ពីការងារ ដោយពុំមានប្រព្រឹត្តិកំហុស បានចូលបំពេញការងារតាមមុខងារដូចសព្វមួយដងវិញ ។

២- សំណើសុំឱ្យក្រុមហ៊ុនគណនាប្រាក់ឈ្នួលនៃអត្រាថែមម៉ោង ចំពោះកម្មករធ្វើតាមបរិមាណផលិតផល (ស៊ីបុង) ឱ្យបានត្រឹមត្រូវ និងសូមទូទាត់ប៉ះប៉ូវឡើងវិញរយៈកាលកន្លងមកដែលផ្តល់មិនត្រឹមត្រូវ ។

៣- សំណើសុំឱ្យក្រុមហ៊ុនតម្លើងថ្លៃបុង និងសូមចេញតំលៃបុងយ៉ាងយូរបំផុត ៣ ថ្ងៃ ក្រោយពីចេញ ភី អូ ថ្មី

៤- សំណើសុំឱ្យក្រុមហ៊ុនចាត់វិធានការតាមច្បាប់ស្តីពីការងារចំពោះប្រធានក្រុម-ផ្នែកចិនទាំងអស់ដែលតែងតែជេរប្រមាថម៉ាក់ងាយមកលើកម្មករនៅពេលមានកំហុសបន្តិចបន្តួច ។

៥- សំណើសុំឱ្យក្រុមហ៊ុនកុំដាក់ទោសពិន័យមិនសមហេតុផល និងសុំបញ្ឈប់ការជេរប្រមាថម៉ាក់ងាយមកលើកម្មករដែលមិនបានស្ម័គ្រចិត្តធ្វើការថែមម៉ោងជូនក្រុមហ៊ុន ។

៦- នៅពេលបញ្ឈប់កម្មករណាម្នាក់ សុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់បំណាច់ផ្សេងៗ តាមច្បាប់ស្តីពីការងារ ។

៧- សុំកុំមានការរើសអើងចំពោះថ្នាក់ដឹកនាំសហជីព និងអ្នកចូលរួមជាសមាជិកសហជីព ។

៨- សុំក្រុមហ៊ុនបើកប្រាក់ឈ្នួល ៥០ ភាគរយ និងប្រាក់បន្ទាប់បន្សំជូនដល់ស្ត្រីឈប់សម្រាកសម្រាលកូនរៀងរាល់បំណាច់ខែនីមួយៗ ។

៩- នៅពេលក្រុមហ៊ុនតម្រូវឱ្យកម្មករជួយធ្វើការថែមម៉ោងដល់ម៉ោង ៨ យប់ សុំឱ្យក្រុមហ៊ុនរៀបចំមធ្យោបាយជូនដំណើរកម្មករដល់លំនៅដ្ឋានរៀងៗខ្លួន និងដោយសុវត្ថិភាព ។

១០- សុំឱ្យក្រុមហ៊ុនអនុញ្ញាតច្បាប់ដល់កម្មករឱ្យមានភាពងាយស្រួលតាមការជាក់ស្តែង និងចំពោះស្ត្រីដែលទើបសម្រាលកូនរួច ហើយមិនទាន់មានសុខភាពល្អបរិបូរណ៍នោះ សុំឱ្យក្រុមហ៊ុនអនុញ្ញាតច្បាប់បន្ត ។

១១- សុំឱ្យក្រុមហ៊ុនសំអាតបង្គន់ឱ្យមានអនាម័យ និងផ្តល់ទឹកប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ។

១២- នៅពេលកម្មករមកធ្វើការយឺតម្តងម្កាល សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករចូលធ្វើការធម្មតា និងសុំរក្សាប្រាក់រង្វាន់ទៀងទាត់នៅដដែល ។

ភាគីកម្មករនិយោជិតបានបញ្ជាក់ថា បើចំណុចទី១ ដោះស្រាយមិនបានសះជាទេនោះ លក្ខខណ្ឌការងារទាំង ១១ ចំណុច គាត់មិនបន្តធ្វើការដោះស្រាយឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៨៤៣/១០ ក.ប/មខសន ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ (វេលាម៉ោង ១៤ :០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធីៈ**

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត ស្តីពីការជូនដំណឹងកូដកម្ម-បាតុកម្មអហិង្សា ដើម្បីទាមទារក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញ និងទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ លុះដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ កម្មករនិយោជិតបាននាំគ្នាធ្វើកូដកម្ម ដើម្បីទាមទារឱ្យថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញ ។ ទន្ទឹមនឹងនោះដែរ មន្ទីរការងារក៏បានធ្វើការផ្សះផ្សាលើកចុងក្រោយ នៅថ្ងៃទី០៥ វិច្ឆិកា ឆ្នាំ២០១០ ប៉ុន្តែ ពុំបានទទួលលទ្ធផលសះជាទេលើការទាមទារចំនួន ១២ ចំណុចនេះ ។ ចំណុចមិនសះជាទាំងនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញ ភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១២ ចំណុចនេះ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល)។ ប៉ុន្តែ ភាគីកម្មករនិយោជិតអវត្តមាន ដោយមិនមានមូលហេតុត្រឹមត្រូវ។ ចំណែកឯភាគីនិយោជកវិញបានអញ្ជើញមក ចូលរួមតាមការកោះអញ្ជើញ របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា ដូចខាងក្រោម:

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនាយករងក្រុមហ៊ុន ភី វ៉ាយ ជូនលោកមេធាវី ហំ ភា ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២- សារណាវិវាទការងាររួម លេខ ០៤៧ កហភ/១០ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣- ដីការសម្រេចរក្សាការពាររបស់សាលាដំបូងខេត្តព្រះសីហនុ លេខ ៣១៥/តរ ១០ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតរបស់សហព័ន្ធសហជីបសិទ្ធិប្រយោជន៍កម្មករ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ គោរពជូន លោកស្រីប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីការសុំពន្យាពេលសវនាការលើសំណុំ រឿងលេខ ១២៦/១០ ។

២- លិខិតរបស់សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករលេខ ៩៤ សសសបក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០១០ គោរពជូន លោកស្រីប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីការស្នើសុំឱ្យ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើសវនាការសំណុំរឿងលេខ ១២៦/១០ របស់កម្មករនិយោជិត ភីវ៉ាយ ឡើងវិញ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ភី វ៉ាយ លេខ ៨៤៣/១០ ក.ប/ មខសន ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ភី វ៉ាយ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១០។

## ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៦៥៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៦៦០ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួមគ
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

## ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុទាក់ទងនឹងការទាមទារទាំងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិតអវត្តមាននៅថ្ងៃសវនាការ ដោយគ្រាន់តែមានតំណាងសហព័ន្ធសហជីពសិទ្ធិប្រយោជន៍ លោក ហ៊ីង ប៊ុនធឿន មកចូលរួម។ ប៉ុន្តែ លោកពុំមានលិខិតផ្ទេរសិទ្ធិពីភាគីកម្មករនិយោជិតមកធ្វើជាតំណាង ដើម្បីចូលរួមសវនាការទេ។ លោក ហ៊ីង ប៊ុនធឿន បានបញ្ជាក់ថា គាត់មកនេះ គឺគ្រាន់តែជូនដំណឹងពីការមិនបានចូលរួមរបស់ថ្នាក់ដឹកនាំសហជីពនៅក្នុងសវនាការ ដោយសារថ្នាក់ដឹកនាំសហជីពទាំងអស់មានធុរៈផ្ទាល់ខ្លួន ដូចដែលមានបញ្ជាក់នៅក្នុងលិខិតស្នើសុំពន្យាពេលសវនាការ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០។

## ហេតុផលនៃសេចក្តីសម្រេចៈ

តាមប្រការ ២១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ "* ។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *" ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន "* ។

ផ្អែកលើប្រការ ២១ និងវិធាន ៤.៧ ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់លេខ ៣០/០៥-មូវៀ. លេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ឹម និង វ៉េ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-រិល សិន និងលេខ ០៩/០៩-នីមបឹស ចិចថាយ៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញមុនពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ។ លក្ខខណ្ឌទី២ គឺ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺ ភាគីមិនបានផ្តល់មូលហេតុសម្រាប់ការមិនបង្ហាញខ្លួន។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរ ឬអត់?

**លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ**

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរអាជ្ញាកណ្តាល។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើលិខិតអញ្ជើញជាផ្លូវការទៅកាន់ភាគីទាំងពីរ។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងដោយនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងទៅកាន់ភាគីអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃថ្ងៃសវនាការតាមរយៈលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ និងតាមទូរស័ព្ទ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី២: ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ប្រការ ១៩ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ ។"*

បន្ថែមពីនេះទៀត ប្រការ ២០ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ..... ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម។"*

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតមិនបានចូលរួមសវនាការទេ ហើយក៏មិនបានផ្ទេរសិទ្ធិត្រឹមត្រូវឱ្យតំណាងណាម្នាក់មកចូលរួមដោះស្រាយវិវាទនេះទេ គឺភាគីកម្មករនិយោជិតគ្រាន់តែឱ្យតំណាងសហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ លោក ហ៊ីង ប៊ុនធឿន មកស្នើសុំពន្យាពេលសវនាការតែប៉ុណ្ណោះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា លោក ហ៊ីង ប៊ុនធឿន មិនអាចតំណាងឱ្យភាគីកម្មករនិយោជិតបានទេ ព្រោះមិនមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវពីភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានបង្ហាញខ្លួននៅក្នុងសវនាការទេ។ ហេតុនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី៣: ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតមិនបានបង្ហាញខ្លួននៅក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ គ្រាន់តែឱ្យតំណាងសហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ លោក ហ៊ីង ប៊ុនធឿន មកស្នើសុំពន្យាពេលសវនាការតែប៉ុណ្ណោះ។ លោក ហ៊ីង ប៊ុនធឿន បានបញ្ជាក់ថា ថ្នាក់ដឹកនាំសហជីពមិនអាចមកចូលរួមសវនាការបានទេ ដោយហេតុថា ប្រធានសហជីពត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ ហេតុនេះហើយគាត់ពុំមានលទ្ធភាពចេញសោហ៊ុយធ្វើដំណើរ ដើម្បីមកធ្វើការដោះស្រាយចំណុចវិវាទទាំងនេះ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ចំណែកឯអនុប្រធានសហជីព និងលេខាសហជីពជាប់រវល់ធុរៈផ្ទាល់ខ្លួន។ ប៉ុន្តែលោក ហ៊ីង ប៊ុនធឿន មិនបានបញ្ជាក់ទេថា តើធុរៈផ្ទាល់ខ្លួននោះ មានភាពចាំបាច់យ៉ាងណាដែលធ្វើឱ្យពួកគាត់ខកខានមិនបានមកចូលរួមសវនាការ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ហេតុផលដែលភាគីកម្មករនិយោជិតខកខានមិនមកចូលរួមសវនាការនេះ មិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលពន្យាពេលសវនាការនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ជាសរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ១២៦/១០-ភី វ៉ាយ នេះដោយភាគីកម្មករនិយោជិតមិនមានវត្តមាននៅពេលសវនាការ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផល ដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

# សម្រេច និង បង្គាប់

បិទសំណុំរឿងលេខ ១២៦/១០-ភី វ៉ាយ អ៊ិនធើណេសិនណល។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **យូ សួនធី**

ហត្ថលេខា: ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------